WWF BRIEF 2014

# ព័ត៌មានសង្ខេបអំពីទំនប់ដនសាហុង

## មានហានិភ័យខ្ពស់ណាស់សម្រាប់ប្រទេសកម្ពុជា

**ខែ មករា ឆ្នាំ ២០១៤**

**សារសំខាន់ៗ ៖**

- ទំនប់ដនសាហុង នឹងបិទព្រែកតែមួយគត់ដែលសមស្របសម្រាប់បម្លាស់ទីពេញមួយឆ្នាំរបស់មច្ឆាជាតិ រវាងប្រទេសកម្ពុជា ឡាវ និង ថៃ
- បណ្តាលឲ្យមានហានិភ័យខ្ពស់ណាស់សម្រាប់ជលផលជាតិនិងជលផលមូលដ្ឋាន ដោយផលប៉ះពាល់ទំនងជានឹងមាននៅក្នុងទូទាំងតំបន់អាងទន្លេមេគង្គប៉ែកខាងក្រោម និង នាំឲ្យមានផលវិបាកយ៉ាងហោចណាស់ ៧៥% ចំពោះសន្តិសុខស្បៀងនិងអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជា និងសេដ្ឋកិច្ចជាតិកម្ពុជា។
- បច្ចុប្បន្ន គេពុំឃើញមានវិធីសាស្ត្រច្បាស់លាស់ដើម្បីកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីទំនប់លើជលផលទន្លេមេគង្គនៅឡើយទេ។
- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង ឯកសារគាំទ្រ ដែលដាក់ជូនដោយក្រុមហ៊ុនម៉េហ្គាហ្វឺស្ត (Mega First) គឺបង្ហាញពីវិធីសាស្ត្រមិនសមស្រប រួមជាមួយនឹងអនុសាសន៍ដែលមិនត្រូវបានគាំទ្រដោយភស្តុតាងវិទ្យាសាស្ត្រឡើយ។
- ផលចំណេញហិរញ្ញវត្ថុនៃទំនប់ដែលមានតម្លៃ ៣០០ លានដុល្លារអាមេរិក គឺមានកម្រិត និង មិនសមាមាត្រជាមួយនឹងហានិភ័យដ៏ធ្ងន់ធ្ងរដែលនឹងកើតមានឡើងទេ ។
- ការសាងសង់និងការប្រតិបត្តិការរបស់ទំនប់ ទំនងជានឹងពន្លឿនការផុតពូជនៃសត្វផ្សោតទន្លេមេគង្គចំនួន ៨៥ក្បាល ដែលជាប្រភេទរងគ្រោះជិតផុតពូជ

## ទំនប់ដនសាហុង

គម្រោងទំនប់ដនសាហុងដែលមានថាមពល ២៦០ មេហ្គាវ៉ាត់ គឺជាគម្រោងមួយនៃគម្រោងវារីអគ្គិសនីចំនួនដប់ពីរ ដែលបច្ចុប្បន្នកំពុងត្រូវបានសិក្សា និងស្នើឡើងសម្រាប់សាងសង់នៅប៉ែកខាងក្រោមនៃទន្លេមេគង្គ។ ទំនប់ដង សាហុងស្ថិតនៅចម្ងាយ ២ គីឡូម៉ែត្រពីព្រំដែនឡាវ-កម្ពុជា ក្នុងខេត្តចំប៉ាសាក់ ប្រទេសឡាវ។ ទំនប់នេះនឹងបិទព្រែកហ៊ូសាហុង ដែលជាព្រែកសំខាន់មួយសំរាប់រដូវប្រាំងរួមមានល្បាក់ខោននៃទន្លេមេគង្គ។

ទំនប់ដនសាហុង នឹងក្លាយជាទំនប់ទីពីរ បន្ទាប់ពីទំនប់សាយ៉ាបូរី ដែលស្ថិតនៅក្នុងប្រទេសឡាវផងដែរ ដែលនឹងត្រូវអនុម័តសម្រាប់ការសាងសង់លើដងទន្លេមេគង្គប៉ែកខាងក្រោម។ ប្រទេសឡាវបានកំណត់អាទិភាពលើការអភិវឌ្ឍវារីអគ្គិសនី ដោយមានអគ្គិសនីផលិតពីទំនប់ដនសាហុង និង ទំនប់សាយ៉ាបូរី ដែលត្រូវបានគ្រោងសម្រាប់នាំចេញទៅកាន់ប្រទេសថៃ។ ប្រទេសឡាវ សម្បូណ៌ធនធានទឹកដែលអាចប្រើសម្រាប់បង្កើតប្រាក់ចំណូលដ៏ចាំបាច់ ហើយវាគឺជាជំហានដ៏ឆ្លាតវៃប្រសិនបើរដ្ឋាភិបាលឡាវ ប្រកាន់យកគម្រោងដែលមានហានិភ័យទាប ដើម្បីបំពេញសេចក្តីត្រូវការផ្នែកថាមពលរបស់ខ្លួន និង ធ្វើឲ្យមានតុល្យភាពចំពោះសក្តានុពលនៃការអភិវឌ្ឍពេលអនាគត ដើម្បីបំរើប្រយោជន៍ ប្រជាជនខ្លួន និង បណ្តាសហគមន៍នៅខាងក្រោមខ្សែទឹក។

កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៦ រដ្ឋាភិបាលឡាវ និង ក្រុមហ៊ុនវិស្វកម្មនិងវិនិយោគម៉ាឡេស៊ីមួយគឺ សាជីវកម្មម៉េហ្គាហ្វឺស្តប៊ែហាដ (MFCB) បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់មួយដើម្បីសិក្សាលទ្ធភាពខាងបរិស្ថាន សេដ្ឋកិច្ច និង បច្ចេកទេសនៃគម្រោងវារីអគ្គិសនីដនសាហុង។ ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) របស់ក្រុមហ៊ុន PEC Konsult Sdn Bhd និង Australian Power and Water ត្រូវបានជួលដោយក្រុមហ៊ុន MFCB ឲ្យធ្វើការសិក្សាអំពីផលប៉ះពាល់នៃទំនប់ ដែលរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៧[1]។ ស្របពេលជាមួយគ្នានេះដែរ ក៏មានការសិក្សា លើលទ្ធភាពនៃការអនុវត្តគម្រោងផងដែរ ដែលបានបញ្ចប់នៅ ក្នុងខែ តុលា ឆ្នាំ ២០០៧។ ប៉ុន្តែរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានមិន

[1] PEC & APW. 2007. Don Sahong Hydropower Project Lao PDR. Environmental Impact Assessment, Volume 1, Report, 11th July 2017. Prepared for Mega First Corporation Berhad, by PEC Consult Sdn Bhd (PEC) and Australian Power and Water (APW), Vientiane, Lao PDR.

ត្រូវបានទទួលយក ហើយកិច្ចព្រមព្រៀងអភិវឌ្ឍន៍គម្រោងមួយត្រូវបានចុះហត្ថលេខា ដោយមានការបញ្ជាក់អំពី ការសិក្សាឡើងវិញអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង




រូបទី ១ និង ២ ៖ ទីតាំងគម្រោងទំនប់ដែលបង្ហាញជម្រកអន្លង់ទឹកជ្រៅរបស់ សត្វផ្សោត

កិច្ចព្រមព្រៀងសម្បទានមួយសម្រាប់ការសាងសង់ទំនប់ ត្រូវបានចុះហត្ថលេខានៅ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០០៨ រវាងប្រទេសឡាវ និង ក្រុមហ៊ុន MFCB។ ក្នុងខែ មិថុនា ឆ្នាំ ២០០៨ ក្រុមហ៊ុន MFCB បានបង្កើតអាជីវកម្មចម្រុះជាមួយសាជីវកម្ម **អាយ ជេ អេម** (IJM Corporation) សម្រាប់ការអភិវឌ្ឍគម្រោង ដែលនៅក្នុងនោះក្រុមហ៊ុន MFCB មានភាគហ៊ុន ៧០% នៅក្នុងអាជីវកម្មចម្រុះ ខណៈដែលសាជីវកម្ម **អាយ ជេ អេម** (IJM Corporation) មានភាគហ៊ុន ៣០%[2]។ ក្នុងឆ្នាំ ២០១០ ក្រុមហ៊ុនជនសាហុងផៅវ័រ ខាំផានីលីមីតធីត (Don Sahong Power Company Limited) ត្រូវបានបង្កើតឡើងជាសាខាមួយនៃក្រុមហ៊ុន MFCB និង ត្រូវបានចុះបញ្ជីនៅ**កោះវឺរជីន** ដែនដីចក្រភពអង់គ្លេស (British Virgin Islands)។

[2] Intellasia News Service. IJM to undertake Laos hydropower project with MFCB. The Egde Daily. 13th June 2008.

“This text has been translated to the Khmer language by NGO Forum on Cambodia.”

## ភាពមិនចុះសម្រុងគ្នាជាបន្តបន្ទាប់លើនីតិវិធីរបស់គណៈកម្មាធិការទន្លេមេគង្គ ត្រូវតែ ធ្វើការដោះស្រាយ

ក្នុងខែតុលា ឆ្នាំ២០១៣ ប្រទេសឡាវបានជូនដំណឹងដល់គណៈកម្មាការទន្លេមេគង្គ (MRC) អំពីបំណងរបស់ខ្លួនក្នុងការអនុវត្តការសាងសង់ទំនប់ដុង សាហុង។ ពួកគេបានអះអាងថាទំនប់ដនសាហុង "មិនស្ថិតនៅលើដងទន្លេ មេគង្គទេ[3]" ដោយសារទំនប់នេះ គ្រោងសាងសង់លើព្រែកតែមួយក្នុងចំណោមព្រែកជាច្រើនផ្សេងទៀត ដែលហូរកាត់កំណាត់ទន្លេនោះ។ ដូច្នេះហើយ ទើបប្រទេសឡាវបានស្នើសុំប្រើនីតិវិធី "**ការជូនដំណឹងជាមុន**" ជំនួសនីតិវិធី "**ការពិគ្រោះយោបល់ជាមុន**"។ រាល់ការទំនាក់ទំនងទាំងអស់របស់គណៈកម្មការទន្លេមេគង្គកន្លងមក បានបញ្ជាក់ ថា "ទំនប់ដនសាហុងគឺជាទំនប់នៅលើដងទន្លេមេគង្គ"[4]។ ការបញ្ជាក់នេះ មាននៅក្នុងផែនការអភិវឌ្ឍន៍អាងទន្លេ និង ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ នៃទំនប់លើដងទន្លេ មេគង្គ ព្រមទាំង រាល់ឯកសារទាំងអស់ដែលបានអនុម័តដោយរដ្ឋាភិបាលឡាវ។

នីតិវិធីរបស់គណៈកម្មការទន្លេមេគង្គស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និង កិច្ចព្រមព្រៀង (PNPCA) គឺជាលក្ខខណ្ឌមួយនៃកិច្ចព្រមព្រៀងឆ្នាំ ១៩៩៥ នៃគណៈកម្មការទន្លេមេគង្គ។ លក្ខខណ្ឌនេះកំណត់នីតិវិធីសម្រាប់ឲ្យប្រទេសទាំងបួនសហការគ្នាដើម្បីពិនិត្យមើលរួមគ្នាលើទំនប់ណាមួយដែលត្រូវបានស្នើឡើងសម្រាប់សាងសង់លើដងទន្លេ មេគង្គ ជាមួយទស្សនៈមួយដែលត្រូវមានការស្រុះស្រួលគ្នាអំពីប្រការដែលថា តើទំនប់ប្រភេទនេះគប្បីសាងសង់ឬទេ ហើយប្រសិនបើត្រូវសាងសង់ តើត្រូវស្ថិតនៅក្រោមលក្ខខណ្ឌអ្វីខ្លះ។ ជាការឆ្លើយតបទៅនឹងការជូនដំណឹងអំពីទំនប់ដនសាហុងដោយរដ្ឋាភិបាលឡាវ ប្រទេសទាំងបីនៅប៉ែកខាងក្រោមទន្លេមេគង្គ គឺកម្ពុជា វៀតណាម និង ថៃ បានស្នើឲ្យគម្រោងទំនប់ដនសាហុងអនុវត្តតាមនីតិវិធី PNPCA ទាំងស្រុង[5]។

បទពិសោធន៍កន្លងមករបស់ទំនប់សាយ៉ាបូរី ជាទំនប់នៅលើដងទន្លេមេគង្គ ដំបូងគេ ដែលបានប្រើប្រាស់យន្តការ នៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និង កិច្ចព្រមព្រៀង (PNPCA)

---

[3] Mekong River Commision Secretariate. 03 Oct 2013. Lao PDR submits notification on Don Sahong Hydropower Project (http://www.mrcmekong.org/news-and-events/news/lao-pdr-submits-notification-on-don-sahong-hydropower-project/)

[4] Mekong River Commision Secretariate. 2007. Environmental Impact Assessment Report Don Sahong Hydropower Project, Lao PDR. Mekong River Commission Secretariat, Vientianne, Lao PDR, 19 November 2007.

[5] Nations unite against dam, Phnom Penh Post. 02 December 2013.

ដែលមានលក្ខណៈគួរឲ្យបារម្ភ ដោយសារប្រទេសទាំងអស់មិនបានឈានដល់ការស្រុះស្រួលគ្នា ហើយគម្រោងនៅពេលនេះកំពុងដំណើរការសាងសង់ ដែលប្រឆាំងទៅនឹងការណែនាំនៃបណ្តាប្រទេសដែលនៅខ្សែទឹកខាងក្រោម ។ តំណាងនៃប្រទេសជាប់ទន្លេមេគង្គទាំងបួន បានឯកភាពគ្នាក្នុងឆ្នាំ ២០១១ ថានឹងពន្យារពេលសម្រេចចិត្តអំពីការសាងសង់ទំនប់សាយ៉ាបូរី និង ធ្វើការសិក្សារួមគ្នាថែមទៀត (ដែលត្រូវបានហៅថាការសិក្សារបស់ក្រុមប្រឹក្សា) ដើម្បីបំពេញ ទិន្នន័យខ្វះចន្លោះ និងស្វែងយល់អំពីផលប៉ះពាល់ឆ្លងដែនដែលបណ្តាលមកពីទំនប់លើ បរិស្ថាននិងសង្គមនេះ[6]។ ប៉ុន្តែ ក្នុងខែវិច្ឆិកា ឆ្នាំ២០១២ កិច្ចព្រមព្រៀងនេះត្រូវបានទុកមួយឡែកនៅពេល ដែលប្រទេសឡាវបានសម្រេចចិត្តដំណើរការសាងសង់ជាឯកតោភាគី។

ប្រទេសទាំងបួននៅមិនទាន់បានដោះស្រាយចំណុចខ្វះខាតសំខាន់ៗទាំងឡាយ នៅក្នុងនីតិវិធីនៃគណៈកម្មការទន្លេមេគង្គនៅឡើយ ដូច្នេះពួកគេនៅមិនទាន់ឯកភាពគ្នាអំពីការបកស្រាយនីតិវិធីទាំងនេះនៅឡើយ។ បទពិសោធន៍កន្លងមក បង្ហាញថានីតិវិធីទាំងនេះនៅមិនទាន់គ្រប់គ្រាន់នៅឡើយសម្រាប់ការអនុវត្តនៅក្នុងគម្រោងលើដងទន្លេ មេគង្គមួយទៀតទេ។ កង្វះការស្រុះស្រួលអន្តររដ្ឋាភិបាលនេះ បង្ហាញនូវអភិបាលកិច្ចឆ្លងដែនដ៏ផុយស្រួយក្នុងតំបន់ និង ចំណងកាតព្វកិច្ចមានកម្រិតនៃប្រទេសក្រោមកិច្ចព្រមព្រៀងគណៈកម្មការទន្លេមេគង្គ។ ប្រការនេះធ្វើឲ្យមានភាពខ្វះចន្លោះ សម្រាប់ឲ្យតួអង្គផ្នែកឯកជន(អ្នកអភិវឌ្ឍន៍ និង វិនិយោគិន) ឆ្លៀតឱកាសយកចំណេញលើសមត្ថភាពមានកម្រិតរបស់ស្ថាប័នរដ្ឋាភិបាល ដើម្បីជំរុញគម្រោងដែលមិនមាននិរន្តរភាពនានាដែលមានលក្ខណៈមិនអាចទទួលយកបាននៅទីកន្លែងដទៃទៀតក្នុងពិភពលោក។ អាស្រ័យហេតុនេះ នីតិវិធីគណៈកម្មការទន្លេមេគង្គចាំបាច់ត្រូវពិនិត្យមើលឡើងវិញ ហើយនីតិវិធីច្បាស់លាស់ត្រូវបានឯកភាពដោយប្រទេសទាំងបួន មុនពេលដែលគម្រោងលើដងទន្លេណាមួយអាចត្រូវបានស្នើឡើង។

## សារៈសំខាន់នៃល្បាក់ខោន និង ជលផលទន្លេមេគង្គ

ល្បាក់ខោន ដែលជាទីតាំងនៃគម្រោងទំនប់ដនសាហុង ទឹកទន្លេមេគង្គធ្លាក់ចុះប្រហែល ២០ ម៉ែត្រ ចូលទៅក្នុងបណ្តាញដ៏ស្មុគ្រស្មាញមួយនៃព្រែកនានាដ៏ចង្អៀត។ ក្នុងចំណោមព្រែកទាំងនេះ ព្រែកហ៊ូសាហុងជាព្រែកពិសេសមួយដែលបំពេញតួនាទីដ៏សំខាន់ នៅក្នុងការបម្លាស់ទីរបស់មច្ឆាជាតិក្នុង អាង

[6] Xayaburi dam delay pending further studies is a positive step, WWF. 08 December 2011 (http://wwf.panda.org/?202755/Xayaburi-dam-delay-pending-further-studies-is-a-positive-step)

"This text has been translated to the Khmer language by NGO Forum on Cambodia."

ទន្លេទាំងមូល ដោយសារវាមានទំហំទទឹងទូលាយ និង មិនមានឧបសគ្គធម្មជាតិនៅក្នុងប្រវែង ៧ គីឡូម៉ែតធ្វើឲ្យវាមានលក្ខណៈងាយស្រួលសម្រាប់មច្ឆាជាតិច្រើនប្រភេទធ្វការផ្លាស់ ទីឡើងទៅទន្លេមេគង្គលើពីប្រទេសកម្ពុជាទៅកាន់ល្បាក់ខោនក្នុងប្រទេសឡាវ[7]។ ក្នុងចំណោមប្រភេទមច្ឆាជាតិដែលគេដឹងពីវដ្តជីវិតរបស់វា ក្នុងនោះមាន៨៧% គឺជាប្រភេទធ្វើបម្លាស់ទី និង ភាគច្រើនមានលក្ខណៈសំខាន់ផ្នែកពាណិជ្ជកម្ម[8]។

តម្លៃសេដ្ឋកិច្ចនៃសេវាអេកូឡូស៊ីទន្លេមេគង្គ មានលក្ខណៈធំធេងណាស់។ ជលផលធម្មជាតិ គឺសំខាន់ក្រៃលែងចំពោះប្រទេសជាប់ទន្លេមេគង្គទាំងអស់។ ជាមួយតម្លៃជលផលតែមួយមុខប៉ុណ្ណោះត្រូវបានគេប៉ាន់ស្មានថាមានតម្លៃពី ១,៤ ពាន់លាន–៣,៩ ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ តួលេខនេះមិនរាប់បញ្ចូលតម្លៃសេដ្ឋកិច្ចជលផលចិញ្ចឹមជីវិតប្រចាំថ្ងៃ ដែលផ្តល់អាហារជូនប្រជាជនរាប់លាននាក់ដែលរស់នៅក្នុងអាងទន្លេនេះទេ។ កសិកម្មគឺជាវិស័យសេដ្ឋកិច្ចចម្បងគេនៅក្នុងអាងទន្លេមេគង្គ ហើយធនធានទឹកសាបនៃប្រព័ន្ធអេកូឡូស៊ីនេះមានសារៈសំខាន់ក្រៃលែងចំពោះការផលិតស្បៀងអាហារ។ ជលផលទឹកសាប ជាពិសេស ជលផលចាប់បានពីធម្មជាតិ មានចំនួនពី ៤៧% ដល់ ៨០% នៃប្រូតេអ៊ីនសត្វដែលបរិភោគដោយប្រជាជនដែលរស់នៅក្នុងអាងទន្លេមេគង្គប៉ែកខាងក្រោម។ ប្រហែល ៧៥% នៃប្រជាជននៃអាងទន្លេពឹងផ្អែកលើកសិកម្មនិងជលផលសម្រាប់ជីវភាពរបស់ពួកគេ។

ជលផលទន្លេមេគង្គ មានសារៈសំខាន់ខាងជីវភាពជាពិសេសចំពោះប្រជាជនកម្ពុជា ដែលរបបអាហារពួកគេ ជាធម្មតាបានមកពីបាយ ត្រី និង បន្លែ។ ធនធានជលផលជាតិមានចំនួន ១៨% នៃបរិមាណអាហារដែលមនុស្សម្នាក់បរិភោគក្នុងមួយថ្ងៃ និង ជាប្រភពចម្បង (៧៦%) នៃប្រូតេអ៊ីនសត្វ[9]។

## ពិសោធន៍សាកល្បងរបស់ប្រទេសឡាវគម្រោងគំហែងដល់ធនធានជលផលក្នុងតំបន់

គម្រោងវារីអគ្គិសនីដនសាហុង អាចមានផលប៉ះពាល់ធំធេងលើធនធានជលផល សន្តិសុខស្បៀង និងជីវភាពប្រជាជន ដោយសារវាបិទព្រែកបម្លាស់ទីដ៏សំខាន់របស់មច្ឆាជាតិនៅក្នុងទន្លេមេគង្គ និង

---

[7] Baird, I.G. 1996. Khone Falls Fishers: Catch and Culture (MRC Newsletter), vol.2, no. 2, November 1996.
[8] Baran, E. 2006. Fish migration triggers in the Lower Mekong Basin and other freshwater tropical systems. MRC Technical Paper no. 14. Mekong River Commission, Vientiane, Lao PDR. 56 pp.
[9] IFReDI. 2012. Mainstream dams in Cambodia and their impact on food security. Inland Fisheries Research and Development Institute, Fisheries Administration, Cambodia.

ជាពិសេស ច្រកឆ្លងកាត់តែមួយគត់ដែលជួយសម្រួលបម្លាស់ទីនារដូវប្រាំង[10]។ ចំណុចនេះនឹងរួមចំណែកដោយជៀសមិនផុត ដល់ការធ្លាក់ចុះថែមទៀតនៃជលផលនៅក្នុងទូទាំងអាងទន្លេមេគង្គប៉ែកខាងក្រោម។

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងឯកសារគាំទ្រ ដែលត្រូវបានដាក់ជូនដោយក្រុមហ៊ុនម៉េហ្គាហ្វឹស (Mega First) មានភាព ខ្វះចន្លោះនូវព័ត៌មានក្នុងការវាយតម្លៃពេញលេញលើផលប៉ះពាល់សំខាន់ៗចំពោះបម្លាស់ទីនៃមច្ឆាជាតិទន្លេមេគង្គដែលទំនប់ដនសាហុងអាចបង្កើតឡើង។ ការព្រួយបារម្ភផ្សេងទៀត រួមមានអនុសាសន៍ដែលមិនត្រូវបានគាំទ្រដោយភស្តុតាងវិទ្យាសាស្ត្រ កង្វះការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន កង្វះចំណេះដឹងភូមិសាស្ត្រជាក់លាក់អំពីសេវាកម្មប្រព័ន្ធអេកូឡូស៊ី អេកូឡូស៊ី និង ប្រភេទមច្ឆាជាតិ ជីវភាព និង ការបង្ហាញភស្តុតាងផ្ទុយពីការពិតការប្រើប្រាស់វិធីសាស្ត្រមិនសមស្រប និង ការលើកឡើងដោយគ្មានខ្លឹមសារ[11]។

គម្រោងទំនប់ដងសាហុងនេះ មានចេតនាសម្រាល ផលប៉ះពាល់លើវិស័យជលផល រួមមានវិធីសាស្ត្រសាកល្បងកែព្រែកតូចៗនៅជិតទំនប់ ដោយសង្ឃឹមថាមច្ឆាជាតិដែលមិនអាចធ្វើបម្លាស់ទីតាមព្រែកហ៊ូសាហុង នឹងធ្វើចលនាឆ្លងកាត់ព្រែកទាំងនេះវិញ។ វិធីសាស្ត្រនេះ នឹងបន្តធ្វើការសាកល្បងរហូតដល់ពេលដែលបង្ហាញថាមច្ឆាជាតិអាចឆ្លងកាត់ព្រែកទាំងនេះបាន។ នេះជាវិធីសាស្ត្រដ៏គ្រោះថ្នាក់ដែលមិនអាចទទួលយកបាន។ វិធានការសម្រាលផលប៉ះពាល់ដែលស្នើឡើងដោយក្រុមហ៊ុនម៉េហ្គាហ្វឹស (Mega First) មិនដែល ទទួលបានភាពជោគជ័យក្នុងការអនុវត្ត នៅក្នុងអាងទន្លេមេគង្គ ឬក្នុងទន្លេតំបន់ត្រូពិកផ្សេងទៀតទេ ហើយក៏មិនមាន សង្ឃឹមថាធានាបានជោគជ័យឡើយ។ ដោយគ្មានភស្តុតាងណាមួយអំពីប្រសិទ្ធភាពនៃបច្ចេកវិទ្យាដែលបានស្នើឡើងរបស់ពួកគេ ក្រុមហ៊ុនម៉េហ្គាហ្វឹស (Mega First) និង ទំនប់ដនសាហុង រំលោភបំពានដោយផ្ទាល់លើគោលការណ៍ណែនាំបឋមរបស់គណៈកម្មការទន្លេមេគង្គ ដែលតម្រូវឲ្យមានអត្រា៩៥%នៃប្រសិទ្ធភាពឆ្លងកាត់របស់មច្ឆាជាតិផលប៉ះពាល់ដែលអាច កើតមានឡើងបណ្តាលមកពីការសាងសង់ទំនប់មួយកាត់ដងទន្លេមេគង្គ មុខជាមានលក្ខណៈអន្តរាយ។ ទំនប់ដនសាហុងអាចបណ្តាលឲ្យមានការខូចខាតដែលមិនអាច

[10] ICEM. 2010. Strategic Environmental Assessment (SEA) of hydropower on the Mekong mainstream, final report, Prepared for the Mekong River Commission by International Centre for Environmental Management. Hanoi, Viet Nam.
[11] WWF. 2013. Preliminary concerns about the EIA and management plans for the Don Sahong Dam – a scientific review (unpublished).

សស្តារឡើយវិញបានចំពោះផលផលទឹកសាបធំបំផុតនៃពិភពលោក។ ផលប៉ះពាល់ រួមមានការបំបែកប្រព័ន្ធទន្លេជាកំណាត់ៗ ការបំផ្លាញបម្លាស់ទីមច្ឆាជាតិដ៏សំខាន់ ការបាត់បង់ផលផល ការបាត់បង់ឱកាសរកប្រាក់ចំណូលសម្រាប់ទ្រទ្រង់ជីវភាព និង ការបាត់បង់កសិកម្ម។ ការថយចុះនៅក្នុងការផ្គត់ផ្គង់មច្ឆាជាតិ នឹងប៉ះពាល់ដល់អាហារូបត្ថម្ភនិងសុខភាពសាធារណៈរបស់ប្រជាជនកម្ពុជានិងប្រជាជនឡាវ ដែលបណ្តាលឲ្យមានការធ្លាក់ចុះគុណភាពជីវិត និង កំណើនភាពងាយរងជម្ងឺនិងការឆ្លងជម្ងឺ[12]។ ទំនប់ដនសាហុង នឹងធ្វើឲ្យខូចខាតដល់លទ្ធភាពរបស់ប្រទេសកម្ពុជានិងឡាវក្នុងការសម្រេចបាននូវការប្តេជ្ញារបស់ខ្លួនចំពោះគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDG)។

## សត្វផ្សោត ប្រឈមមុខនឹងការផុតពូជ

គេឃើញមានសត្វផ្សោត (*Orcaella brevirostris)* ទទួលរងគ្រោះថ្នាក់ ឈានទៅរកការវិនាសជិតផុតពូជដែល បានចុះក្នុងបញ្ជីក្រហមនៃអង្គការ IUCN ដែលមានតែប្រហែល ៨៥ ក្បាលប៉ុណ្ណោះ មាននៅសល់ក្នុងទន្លេមេគង្គ[13,14]។ សត្វផ្សោតទាំងនេះ គឺជាសត្វផ្សោតទាំងអស់ដែលនៅសល់នៃហ្វូងផ្សោតកាលពីមុនធ្លាប់មាននៅក្នុងដែនដីមួយដែលលាតសន្ធឹងពីល្បាក់ខោននៅប៉ែកចុងខាងត្បូងនៃប្រទេសឡាវ ទៅដល់ខ្សែទឹកប៉ែកខាងក្រោមតំបន់ដីសណ្តរក្នុងប្រទេសវៀតណាម និង ប្រហែលជាចូលជ្រៅទៅក្នុងដៃទន្លេធំៗ ដូចជាទន្លេសាប និង អាងទន្លេសេកុង ជាដើម។ ផ្សោតនៅពេលនេះអាចរកឃើញតែនៅក្នុងតំបន់កាំពី នៅប៉ែកខាងជើងនៃប្រទេសកម្ពុជាទៅដល់ល្បាក់ខោន ក្នុងចម្ងាយត្រង់ប្រហែល ១៩០ គីឡូម៉ែត្រ ដែលជាការធ្លាក់ចុះ ៨៦% នៅក្នុងរបាយប្រវត្តិសាស្ត្រនៃសត្វផ្សោត។

អន្លង់ទឹកជ្រៅគឺជាជម្រកដ៏សំខាន់មួយសម្រាប់មច្ឆាជាតិនិងផ្សោតនារដូវប្រាំងក្នុងទន្លេមេគង្គ[15]។ នៅជាប់ខាងក្រោមល្បាក់ខោន គឺជាអន្លង់ទឹកជ្រៅមួយដែលស្ថិតនៅលើព្រំដែនរវាងប្រទេសកម្ពុជានិង

---

[12] Baird, I. 2011. The Don Sahong Dam: Potential impacts on regional fish migrations, livelihoods, and human health. Critical Asian Studies, 43:211-235.

[13] Smith, B.D. & I. Beasley. 2004. Orcaella brevirostris (Mekong River subpopulation). In: IUCN 2013. IUCN Red List of Threatened Species. Version 2013.1. www.iucnredlist.org.

[14] Ryan, G.E., V. Dove, F.T. Trujillo, & P.F. Doherty Jr. 2011. Irrawaddy dolphin demography in the Mekong River: an application of mark-resight models. *Ecosphere* 2(5): art58.

[15] Poulsen, A., Ouch, P., S. Viravong, U. Suntornratana & Nguyen T.T. 2002. Deep pools as dry season fish habitats in the Mekong Basin. MRC Technical Paper No. 4, Mekong River Commission, Phnom Penh. 22 pp. ISSN: 1683-1489

ឡាវ[16]។ មាននៅសល់ផ្សោតតែប្រាំមួយក្បាលប៉ុណ្ណោះដែលនៅដាច់ពីគេក្នុងអន្លង់ឆ្លងដែននេះ។ ផ្សោតទាំងនេះ គឺជាផ្សោតនៅសល់ចុងក្រោយបំផុតនៅក្នុងប្រទេសឡាវ[17,18]។

ដោយសារស្ថានភាពជិតដាច់ពូជធ្ងន់ធ្ងរនៃសត្វផ្សោតនៃទន្លេមេគង្គ ដែនដីដ៏ចង្អៀត និង ចំនួនថយចុះរបស់វា[19] មានតែសកម្មភាពមានហានិភ័យទាបបំផុតប៉ុណ្ណោះដែលសមស្របនឹងការរស់រាននៃផ្សោតក្នុងប្រទេសឡាវ និង ទន្លេមេគង្គ។

អ្នកគាំទ្រទំនប់ដនសាហុង បានបញ្ជាក់ថាពុំមាន "ផលប៉ះពាល់ធ្ងន់ធ្ងរ" លើសត្វផ្សោតទេ[20] ប៉ុន្តែការពិនិត្យមើលឡើងវិញមួយដោយអ្នកឯកទេស លើឯកសារវាយតម្លៃហេតុប៉ះពាល់នៃគម្រោងបានសន្និដ្ឋានថាទំនប់ដនសាហុងនឹងប៉ះពាល់សត្វផ្សោតដោយផ្ទាល់តាមរយៈការសាងសង់ និងកិច្ចប្រតិបត្តិការទំនប់ និង ប៉ះពាល់ដោយប្រយោលតាមរយៈផលប៉ះពាល់ជាបន្តបន្ទាប់លើពពួកសត្វផ្សោតនេះ និងលើបរិស្ថានជុំវិញដែលមានវិសាលភាពធំទូលាយ។ ហើយផលប៉ះពាល់នៃទំនប់នេះប្រហែលជាមិនអាចបន្ធូរបន្ថយបានឡើយ[21] និងពិតជាមិនអាចសម្រាលបានទេបើការសាងសង់នេះផ្អែកតាមផែនការបច្ចុប្បន្នដែលមានចែងនៅក្នុងឯកសារវាយតម្លៃហេតុប៉ះពាល់នៃគម្រោងនេះ [20,22,23]។ម្យ៉ាងទៀតការបាត់បង់ជម្រកនៅក្នុងអន្លង់ឆ្លងដែននៅខាងក្រោមល្បាក់ខោននឹងធ្វើឲ្យមានការថយចុះប្រហែលជា ៣៥% ចំពោះកម្រិតនៃការបង្ហាញខ្លួនរបស់សត្វផ្សោតនៅក្នុងទន្លេមេគង្គ។ ដោយហេតុនេះ ធ្វើឲ្យហ្វូងសត្វផ្សោតក្នុងទន្លេមេគង្គទាំងមូលស្ថិតក្នុងហានិភ័យដ៏ធំនៃការផុតពូជក្នុងពេលអនាគតដ៏ខ្លី។ ការបាត់

---

[16] Baird, I.G. & B. Mounsouphom. 1997. Distribution, mortality, diet and conservation of Irrawaddy dolphins (Orcaella brevirostris) in Lao PDR. *Asian Marine Biology* 14: 41–48.
[17] Ryan, G.E. 2012. Last chance for dolphins in Laos: a review of the history, threats, and status. A Technical Report from WWF-Greater Mekong Programme, Hanoi, Vietnam.
[18] Ryan, G.E. 2013. Is the extirpation of Irrawaddy dolphins Orcaella brevirostris in Laos imminent: an assessment of status and recommendations for conservation. Report to the Scientific Committee of the International Whaling Commission, SC/65a/SM05.
[19] Beasley, I., K. Pollock, T.A. Jefferson, P. Arnold, L. Morse, S. Yim, S. Lor Kim, & H. Marsh. 2012. Likely future extirpation of an Asian river dolphin: the critically endangered population of the Irrawaddy dolphin in the Mekong River is small and declining. *Marine Mammal Science* 29(3): E226–E252.
[20] NCC, 2013. Don Sahong Hydropower Project Lao PDR. Environmental Impact Assessment, Final, January 2013. Prepared for Mega First Corporation Berhad, by National Consulting Company (NCC) Vientiane, Lao PDR.
[21] Ryan, G.E. 2013. The Don Sahong Dam and the Mekong Dolphin. An updated review of the potential impacts of the Don Sahong Hydropower Proposal on the Mekong River's Critically Endangered Irrawaddy dolphins *Orcaella brevirostris.* A Science Brief from WWF Cambodia.
[22] NCC, 2013. Don Sahong Hydropower Project Lao PDR (DSHPP), Envrionmental Monitoring and Management Plan, Final, January 2013. Prepared for Mega First Corporation Berhad, by National Consulting Company (NCC) Vientiane, Lao PDR.
[23] NCC, 2013. Don Sahong Hydropower Project Lao PDR. Environmental & Social Studies. Cumulative Impact Assessment, Final.

បង់សត្វផ្សោតនឹងមានផលប៉ះពាល់ខ្លាំងលើទេសចរណ៍ទស្សនាផ្សោតនៃប្រទេសកម្ពុជា ដែលត្រូវបានកំណត់តម្លៃ ៤ លានដុល្លារ[24]។

## តើមានជម្រើសអ្វីផ្សេងទៀតទេ?

ដោយមិនសាងសង់ទំនប់មួយលើព្រែកហ៊ូសាហុង ប្រទេសឡាវមិនមែនធ្វើឲ្យ ថយចុះនូវលទ្ធភាពរបស់ខ្លួនក្នុងការផលិតអគ្គិសនី ឬ មហិច្ឆតាអភិវឌ្ឍន៍របស់ខ្លួនឡើយ។ នៅមានជម្រើសផលិតអគ្គិសនី និង ជម្រើសវារីអគ្គសនីផ្សេងទៀត ដែលបានគ្រោងឡើងដើម្បីឲ្យមានប៉ះពាល់តិច និង មាននិរន្តរភាពផ្នែកបរិស្ថាន[25]។ ការប្រើឧបករណ៍វាយតម្លៃ ដែលមានការពិចារណាខ្ពស់អំពីបញ្ហាបរិស្ថាន ដូចជាពិធីសារស្តីអំពីការវាយតម្លៃនិរន្តរភាពវារីអគ្គិសនី (HSAP) នៃសមាគមវារីអគ្គិសនីអន្តរជាតិ ឬ ឧបករណ៍វាយតម្លៃឆាប់រហ័សពីនិរន្តរភាពនៃទំនប់វារីអគ្គិសនី (RSAT) អាចជួយធ្វើឲ្យយល់និងដាក់បញ្ចូលកត្តាបន្ទាន់និងកត្តាតំបន់នានាទៅក្នុងទីតាំងគម្រោង ផែនការសាងសង់ និង កិច្ចប្រតិបត្តិការ។

គម្រោងបែបនេះ ពោលគឺគម្រោងបង្វែរទឹកថាកូ (Thako) គឺជាគម្រោងវារីអគ្គិសនីមួយដែលមានអនុភាព ១៧២ មេហ្គាវ៉ាត់ ដែលត្រូវបានស្នើឡើងសម្រាប់ដងទន្លេមេគង្គ ដោយប្រើប្រាស់ស្ថានភាពធម្មជាតិពិសេសនៅជិតល្បាក់ខោន។ គម្រោងថាកូ អាចផលិតអគ្គិសនីជិតស្មើគម្រោងដនសាហុង ដោយមានផលប៉ះពាល់បរិស្ថានតិចតួចប៉ុណ្ណោះ។ គម្រោងថាកូ នឹងមិនមានការសាងសង់របាំងណាមួយកាត់ព្រែកណាមួយនៃដងទន្លេមេគង្គឡើយ។ ផ្ទុយទៅវិញ ទឹកនឹងត្រូវបានបង្វែរតាមរយៈព្រែកលើដីមួយដែលត្រូវបានសាងសង់ព័ទ្ធល្បាក់ខោនផាផេង (Khone Phapheng Waterfall)។

បច្ចេកវិទ្យាច្នៃប្រឌិតនេះ នឹងផលតិអគ្គិសនីក្នុងបរិមាណប្រហែលគ្នានឹងទំនប់ដនសាហុងដែរ ប៉ុន្តែ មានផលប៉ះពាល់តិចជាងច្រើន ជាពិសេស ដោយសារគម្រោងត្រូវបានគ្រោងយ៉ាងល្អិតល្អន់ដើម្បីនិរន្តរភាព ហើយពុំមានទំនប់និងអាងស្តុកទឹកទេ។ យន្តការនេះ ធ្វើឲ្យមានគម្រោងវារីអគ្គិសនីមួយដែលពុំមានផលប៉ះពាល់អ្វីឡើយលើបម្លាស់ទីមច្ឆាជាតិនៅខាងលើខ្សែទឹក និង មានផលប៉ះពាល់តិចតួចប៉ុណ្ណោះលើបម្លាស់ទីមច្ឆាជាតិនៅខ្សែទឹកខាងក្រោម។ ហេតុដូច្នេះ វានឹងមិនមានផលប៉ះពាល់ខ្លាំងលើបម្លាស់ទីរបស់មច្ឆាជាតិ និង ដោយហេតុនេះ នឹងមិនបណ្តាលឲ្យមានបញ្ហាក្នុងកម្រិតតំបន់ឡើយ។ ម្យ៉ាងទៀត

[24] O'Connor, S., Campbell, R., Cortez, H., & Knowles, T. 2009. Whale Watching Worldwide: tourism numbers, expenditures and expanding economic benefits, a special report from the International Fund for Animal Welfare, Yarmouth MA, USA, prepared by Economists at Large (http://www.ecolarge.com/work/whale-watching-worldwide/#sthash.ooXm2ATf.dpuf).

[25]

"This text has been translated to the Khmer language by NGO Forum on Cambodia."

នឹងពុំមានការប្រែប្រួលនៅក្នុងរបាយលំហូរទឹករវាងព្រែកផ្សេងៗ និង ពុំចាំបាច់ត្រូវមានការតាំងលំនៅឋានថ្មីរបស់គ្រួសារទាំងឡាយឡើយ ដែលចំណុចទាំងអស់នេះ នឹងកើតឡើងប្រសិនបើទំនប់ដនសាហុងត្រូវបានសាងសង់។

គម្រោងថាកូ ក៏ត្រូវបានគ្រោងធ្វើសមាហរណកម្មជាមួយផែនការគោលទេសចរណ៍សម្រាប់ស្រុកស៊ីផាដោន (Siphandone) ដែលត្រូវបានរៀបចំដោយរដ្ឋបាលជាតិទេសចរណ៍ឡាវ និង ធនាគារអភិវឌ្ឍន៍អាស៊ី និង ដោយហេតុនេះ ធ្វើឲ្យសហគមន៍មូលដ្ឋានអាចទទួលអត្ថប្រយោជន៍ពីកាលានុវត្តភាពទេសចរណ៍។

## សេចក្តីសន្និដ្ឋាន

ទំនប់ដនសាហុង នឹងគម្រាមកំហែងជលផលពាណិជ្ជកម្ម និងជលផលចិញ្ចឹមជីវិត សេដ្ឋកិច្ចតំបន់ សត្វផ្សោត ទទួលការគំរាមកំហែងឈានទៅរកការវិនាសផុតពូជនៃទន្លេមេគង្គ និង វិស័យទេសចរណ៍។ ភស្តុតាងវិទ្យាសាស្ត្រដែលមាននាពេលបច្ចុប្បន្ន បង្ហាញថាទំនប់នេះគឺជាដំណោះស្រាយផលិតអគ្គិសនីគ្មាននិរន្តរភាពលើផ្នែកបរិស្ថាននិងសេដ្ឋកិច្ចទេ។ ប៉ុន្តែ វាមិនទាន់ហួសពេលទេ។ ការសាងសង់នៅមិនទាន់បានចាប់ផ្តើមនៅឡើយ។ អង្គការ WWF អំពាវនាវឲ្យមានការអនុវត្តការធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ និង កិច្ចដំណើរការប្រកបដោយតម្លាភាពនិងដោយមានការចូលរួមមុនពេលធ្វើសេចក្តីសម្រេចណាមួយ។ ប្រសិនបើទំនប់ដនសាហុងត្រូវបានដំណើរការមែន នោះផលវិបាកគឺមានលក្ខណៈធំធេងពេកណាស់។

------------------------------

"This text has been translated to the Khmer language by NGO Forum on Cambodia."

**Why we are here.**
To stop the degradation of the planet's natural environment and to build a future in which humans live in harmony with nature.
www.panda.org

ឯកសារសង្ខេបនេះត្រូវបានរៀបចំដោយអង្គការ WWF-Cambodia
ទូរសព្ទលេខ: +៨៥៥ ២៣ ២១៨ ០៣៤
ទំនាក់ទំនងព័ត៌មាន: asnarith.tep@wwfgreatermekong.com